**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ

## ស្តីពីការប្រជុំនៃការព្យួរការងាររបស់កម្មករនិយោជិត

ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង០១:០០នាទីព្រឹក នៅការិយាល័យរោងចក្រ តាកែវស៊ូ (ខេមបូឌា) ដែលមាន ទីតាំងស្ថិតនៅ ផ្លូវជាតិលេខ២ ភូមិត្រាំ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ មានបើកកិច្ចប្រជុំដោះស្រាយវិវាទការងារ រួមស្តីពី ការព្យួរការងាររបស់កម្មករនិយោជិត ក្រោមអធិបតីភាពលោកស្រី CHUN CHENXIA ជានាយកគ្រប់គ្រងរោងចក្រ តាកែវស៊ូ (ខេមបូឌា) និងមានការចូលរួមពី អ្នកបកប្រែភាសាចិនខ្មែរ ផ្នែករដ្ឋបាល ផ្នែកគណនេយ្យ ផ្នែកសិទ្ធិមនុស្ស តំណាងសហជីពមូលដ្ឋាន ប្រតិភូបុគ្គលិក និងប្រធានផ្នែកសង្វាក់ផលិតកម្មគ្រប់ផ្នែកទាំងអស់ ២៤នាក់។

**ក/សមាសភាពចូលរួម៖** បញ្ជីវត្តមានជូនភ្ជាប់។

**ខ/របៀបវារៈ ៖** ការព្យួរការងាររបស់កម្មករនិយោជិត។

**គ/អំពីសំណូមពររបស់កម្មករនិយោជិត៖** នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើដោយឱ្យកម្មករនិយោជិតឈប់សម្រាករយៈពេលខ្លីៗ ឬក៏រយៈពេលវែង សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ៥០% (ហាសិបភាគរយ) ស្មើនឹង ៩៧ ដុល្លារ/ខែ(កៅសិបប្រាំពីរ)។ ដោយកម្មករបានលើកហេតុផលថា លុយ៥០%នេះគឺដើម្បីយកទៅឱ្យថ្លៃផ្ទះជួល ថ្លៃរថយន្តជិះដាក់ ខែ ហើយម្យ៉ាងទៀតដើម្បីលើកទឹកចិត្តកម្មករនិយោជិតដែលកំពុងមានចំណេះ មានជំនាញ និងមានបទពិសោធន៍ការងារនៅក្នុង រោងចក្រឱ្យនៅតែបន្តបំពេញការងារជាមួយខាងរោងចក្រនេះជាបន្តទៀតផងដែរ។

**ឃ/អំពីសំណូមពររបស់និយោជក៖** ដោយឡែកខាងក្រុមហ៊ុនបានលើកឡើងថា ដោយសារតែវិបត្តិសេដ្ឋកិច្ចសកលបណ្តាលមកពីជំងឺកូវីដ១៩ និងភ្លើងសង្គ្រាមរុស្ស៊ី អ៊ុយក្រែន ទើបធ្វើឱ្យក្រុមហ៊ុនជួបបញ្ហាលំបាកមិនមានការបញ្ជាទិញថ្មី និងការកាត់បន្ថយការបញ្ជាទិញពីភ្ញៀវជាដើម។ ក្នុងស្ថានភាពបែបនេះបានធ្វើឱ្យក្រុមហ៊ុនជួបការលំបាកផ្នែកសេដ្ឋកិច្ចតម្រូវឱ្យក្រុមហ៊ុនបង្ខំចិត្តឱ្យកម្មករនិយោជិតព្យួរការងារមួយរយៈពេលខ្លី និងផ្តល់ប្រាក់ឈ្នួលជូន៥០ដុល្លារ/ខែ។ ចំណែកនីតិវិធីនៃការព្យួរការងារ ក្រុមហ៊ុននឹងអនុវត្តតាមច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ង/អំពីលទ្ធផលនៃអង្គប្រជុំ ៖** ក្រោយពីមានការពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឯកភាពគ្នា និងសម្រេចព្យួរការងារកម្មករនិយោជិត ចំនួន ១១១នាក់ (ស្រី១០៩នាក់) និងមានលក្ខខណ្ឌដូចខាងក្រោម ៖

**ចំណុចទី១៖** ក្នុងរំឡុងពេលព្យួរការងាររយៈពេលវែង ក្រុមហ៊ុននឹងផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិត ចំនួន៧០ដុល្លារ (ចិតសិប) ក្នុងមួយខែ។

**ចំណុចទី២៖** ក្នុងករណីក្រុមហ៊ុនព្យួរការងាររយៈពេលខ្លីៗ ក្រុមហ៊ុននឹងយកប្រាក់៧០ដុល្លារ(ចិតសិប)មកសមាមាត្រតាមចំនួនថ្ងៃដែលបានឈប់សម្រាក។

**ចំណុចទី៣៖** នៅពេលក្រុមហ៊ុនព្យួរការងាររយៈពេលខ្លីៗក្រោមមួយខែ ក្រុមហ៊ុននឹងរក្សាប្រាក់រង្វាន់ការងារម៉ោងទាត់ (លុយព្រីមចំនួន១០ដុល្លារ) និងសោហ៊ុយធ្វើដំណើរ ឬប្រាក់ជួសការស្នាក់នៅ (ចំនួន១១ដុល្លារ) នៅដដែល។

**ចំណុចទី៤៖** ក្នុងករណីក្រុមហ៊ុនព្យួរការងាររយៈពេលវែងពេញមួយខែក្រុមហ៊ុនមិនផ្តល់ប្រាក់រង្វាន់ការងារទៀងទាត់ និងសោហ៊ុយធ្វើដំណើរ ឬប្រាក់ជួសការស្នាក់នៅជូនទេ គឺក្រុមហ៊ុនផ្តល់ឱ្យតែប្រាក់ឈ្នួលចំនួន៧០ដុល្លារ (ចិតសិប) តែប៉ុណ្ណោះ។

**ចំណុចទី៥៖** កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ នេះតទៅ រហូតដល់មានកិច្ច ព្រមព្រៀងថ្មីទៀតមកជំនួស។

អង្គប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោង០១:៤៥នាទីព្រឹក នាថ្ងៃ ខែ ឆ្នាំ ដដែល ដោយក្តីសោមនស្សរីករាយ ក្រោមបរិយាកាសយោគយល់ និងយោគយល់គ្នាទៅវិញទៅមក។

បានឃើញ និងឯកភាព
**ប្រធានអង្គប្រជុំ**

អ្នកធ្វើកំណត់ហេតុ
**ហត្ថលេខា**

ផ្នែករដ្ឋបាល
TAKEO SHOES(Cambodia) Co.,Ltd

陳春霞